ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គភាពគាំពារជនរងគ្រោះ
Victims Support Section
Section d'appui aux victimes

# របាយការណ៍សិក្ខាសាលា
# ស្តីពី
# " ការយល់ដឹងអំពីយេនឌ័រ និងយុត្តិធម៌អន្តរកាល"



កាលបរិច្ឆេទ៖ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១២ នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា

ផ្តល់មូលនិធិដោយ៖

មូលនិធិពិសេសសម្រាប់អង្គការសហប្រជាជាតិដើម្បីលុបបំបាត់អំពើហិង្សាចំពោះនារីភេទ

UNITED NATIONS
TRUST FUND TO
END VIOLENCE
AGAINST WOMEN


Original ERN: 00831704-00831721

**មាតិកា**

I. **ប្រវត្តិ** ........ 4
១. គោលដៅ ........ 4
២. គោលបំណង ........ 4
II. **សិក្ខាសាលា** ........ 5
១. កិច្ចបើកកម្មវិធី ........ 5
២. ការធ្វើបទបង្ហាញពីការយល់ដឹងអំពីយេនឌ័រ និងយុត្តិធម៌អន្តរកាលរបស់លោកស្រី Caitlin Reiger ........ 6
៣.យុត្តិធម៌យេនឌ័រសម្រាប់ឧក្រិដ្ឋកម្មពីអតីតកាលក្នុងប្រទេសឥណ្ឌូនេស៊ី និងប្រទេសទីម័រខាងកើត ........ 8
៤. ដំណើរឆ្ពោះទៅមុខនៃការយល់ដឹងអំពីយេនឌ័រ និងយុត្តិធម៌អន្តរកាលក្នុងប្រទេសកម្ពុជា ........ 8
៥. ការវាយតម្លៃលើសិក្ខាសាលា ........ 18
III. **មិនកម្មវិធី** ........ 29
-ឧបសម្ព័ន្ធ ១៖ របៀបវារៈ ........ 30
-ឧបសម្ព័ន្ធ ២៖ ការបែងចែកភេទរបស់ជនរងគ្រោះ ដែលចូលរួមជាមួយកិច្ចដំណើរការនីតិវិធីរបស់អ.វ.ត.ក ........ 30

ពាក្យកាត់ និងអក្សរបំប្រួញ

| | |
|---|---|
| -ADHOC | សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា |
| -BTS | បន្ទាយស្រី |
| -CCHR | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| -CDP | ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| -CHRAC | គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា |
| -ECCC | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| -LAC | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា |
| -LICADO | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ |
| -LSCW | ជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី |
| -PAS | ផ្នែកកិច្ចការសាធារណៈ |
| -PCC | ការផ្លាស់ប្តូរជាវិជ្ជមានរបស់កម្ពុជា |
| -TPO | អង្គការចិត្តសង្គមអន្តរវប្បធម៌ |
| -VSS | ផ្នែកគាំពារជនរងគ្រោះ |
| -WESU | អង្គភាពគាំពារសាក្សី និងអ្នកជំនាញ |
| -WMC | មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា |
| -YFP | អង្គការយុវសន្តិភាព |
| -UN Women | អង្គការសហប្រជាជាតិស្តីពីសមភាពយេនឌ័រ និងការលើកកម្ពស់អំណាចស្ត្រី |

## I. ប្រវត្តិ

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ ផ្នែកគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដោយសហប្រតិបត្តិការជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) និងក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស (CDP) បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពី "ការយល់ដឹងអំពីយេនឌ័រ និងយុត្តិធម៌អន្តរកាល" ហើយពិធីនេះត្រូវបានធ្វើឡើងនៅសណ្ឋាគារអាំងទែរកង់ទីណង់តាល់។ សិក្ខាសាលានេះត្រូវបានសម្របសម្រួលដោយអ្នកផ្តល់ប្រឹក្សាជំនាញលោកស្រី Caitlin Reiger។ សិក្ខាសាលាមានអ្នកចូលរួមចំនួន៤៣ នាក់ (ស្រីចំនួន២៩ នាក់ បុរសចំនួន១៤ នាក់) ដែលមកពីអង្គការខុសៗគ្នា។

## ១. គោលដៅ

គោលដៅនៃសិក្ខាសាលានេះគឺដើម្បីពិនិត្យមើលការកើតឡើងទូទៅ ពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ និងយេនឌ័រ ក្នុងសម័យខ្មែរក្រហម និងដើម្បីឆ្លៀតឱកាសរកយុត្តិធម៌បន្ថែមពីលើអ្វីដែលអ.វ.ត.ក តែឯកឯងនឹងអាចផ្តល់ឲ្យនោះ។ អ្នកចូលរួមត្រូវបានលើកទឹកចិត្តឲ្យបង្កើតវិធីសាស្ត្រ ប្រកបដោយគំនិតច្នៃប្រឌិតជាច្រើនក្នុងការរិះគិតរកអ្វីដែលជាតម្រូវការដើម្បីធានាថា បញ្ហាយេនឌ័រត្រូវបានដាក់បញ្ចូលក្នុងកិច្ចការងារទទួលខុសត្រូវសម្រាប់រឿងពីអតីតកាល។

## ២. គោលបំណង

សិក្ខាសាលានេះបានផ្តល់ឱកាសល្អមួយក្នុងការស្វែងយល់បន្ថែមអំពីយុទ្ធសាស្ត្រយុត្តិធម៌អន្តរកាល និងស្វែងយល់អំពីរបៀបដែលយុទ្ធសាស្ត្រទាំងនេះត្រូវបានប្រើប្រាស់ ដើម្បីផ្តល់យុត្តិធម៌ចំពោះអំពើហិង្សាផ្លូវភេទនៅក្នុងប្រទេសផ្សេងៗទៀត។ សិក្ខាសាលានេះផ្តល់ឱកាសឲ្យបុគ្គលិកអនុវត្តយុទ្ធសាស្ត្រជាក់ស្តែង ដើម្បីដាក់បញ្ចូលបញ្ហាអំពើហិង្សាផ្លូវភេទទៅក្នុងកម្មវិធីការងារ និងសកម្មភាពនានារបស់ខ្លួន។

## II. សិក្ខាសាលា

### ១. កិច្ចបើកកម្មវិធី



លោក អ៊ឹម សុភា ប្រធានកម្មវិធីផ្សព្វផ្សាយ នៃផ្នែកគាំពារជនរងគ្រោះរបស់អ.វ.ត.ក បានថ្លែងបើកសិក្ខាសាលានេះជំនួសឲ្យលោក រោង ឈុង ប្រធានផ្នែកគាំពារជនរងគ្រោះនិងថ្លែងអំណរគុណជាអនេកដល់វត្តមានរបស់អស់លោកលោកស្រី អ្នកនាងកញ្ញាដែលមានវត្តមានក្នុងសិក្ខាសាលាស្តីពី "ការយល់ដឹងពីយេនឌ័រ និងយុត្តិធម៌អន្តរកាល" នាថ្ងៃនេះ។

កន្លងមក អ.វ.ត.ក/ផ្នែកគាំពារជនរងគ្រោះ ដោយសហការជាមួយក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស (CDP) និងអង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) បានទទួលគម្រោងមួយពីអង្គការសហប្រជាជាតិស្តីពី សមភាពយេនឌ័រ និងការលើកកម្ពស់អំណាចស្ត្រី (ស្ត្រី អ.ស.ប) ស្តីពី "ការលើកកម្ពស់សមភាពយេនឌ័រ និងការធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌របស់ស្ត្រីរងគ្រោះ និងជនរងគ្រោះផ្នែកហិង្សាផ្លូវភេទ ក្រោមរបបខ្មែរក្រហម" ចាប់ពីខែតុលា ឆ្នាំ២០១១ ដល់ខែកញ្ញា ឆ្នាំ២០១២។

អង្គការដែលធ្វើការងារលើរឿងអតីតកាលខ្មែរក្រហមជាច្រើនកំពុងចោទសំណួរថា៖

តើអ្វីទៅជាយុត្តិធម៌អន្តរកាល?
តើអ្វីទៅជាការយល់ដឹងអំពីយេនឌ័រ?
តើយេនឌ័រមានទំនាក់ទំនងយ៉ាងណាទៅនឹងយុត្តិធម៌អន្តរកាល?

លោកអ៊ឹម សុភា បានធ្វើការណែនាំឲ្យស្គាល់អ្នកសម្របសម្រួលសិក្ខាសាលានេះគឺលោកស្រី Caitlin Reiger។ លោកស្រីគឺជាអ្នកជំនាញយូរឆ្នាំមួយរូប ក្នុងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល (ICTJ)។

ជាចុងក្រោយ លោក អ៊ឹម សុភា ជឿថា យើងទាំងអស់គ្នានឹងទទួលបានចំណេះដឹងបន្ថែម ព្រមទាំងផ្លាស់ប្តូរ

ទស្សនៈគ្នាទៅវិញទៅមកបានល្អជាមួយអ្នកចូលរួមផ្សេងៗទៀត។

ជាថ្មីម្តងទៀត លោក អ៊ឹម សុភា ថ្លែងអំណរគុណជាអនេកដល់លោកលោកស្រី ដែលបានចំណាយពេលវេលា និងត្រៀមជាស្រេច ដើម្បីចូលរួមក្នុងសកម្មភាពជជែកពិភាក្សាគ្នានៅក្នុងសិក្ខាសាលានេះ។ ខ្ញុំសង្ឃឹមថា លោកលោកស្រី នឹងទទួលបានលទ្ធផលជាទីគាប់ប្រសើរមកវិញ ហើយខ្ញុំសូមប្រកាសបើកសិក្ខាសាលានៅពេលនេះ។

**២. ការធ្វើបទបង្ហាញពីការយល់ដឹងអំពីយេនឌ័រ និងយុត្តិធម៌អន្តរកាលរបស់លោកស្រី Caitlin Reiger**

បន្ទាប់ពីមតិស្វាគមន៍បើកសិក្ខាសាលា លោកស្រី Caitlin Reiger បានផ្តល់សេចក្តីសង្ខេបអំពីយុត្តិធម៌អន្តរកាលថាជាដំណើរការ និងជាយន្តការពេញលេញដែលស្របគ្នានឹងកិច្ចខិតខំប្រឹងបែងរបស់សង្គម ដើម្បីចងក្រងកេរតំណែលមួយស្តីអំពីការរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំ។ លោកស្រីបានបន្ថែមថា ដំណើរការពេញលេញនានាទាំងក្នុង និងក្រៅប្រព័ន្ធយុត្តិធម៌ ក៏ដូចជាផែនការការងារច្បាប់ដែលគាំទ្រដល់សិទ្ធិជនរងគ្រោះថាជាការលុបបំបាត់ដ៏មានប្រសិទ្ធភាព លែងឲ្យមានការរំលោភបំពានធ្ងន់ធ្ងរតទៅទៀត។ បន្ទាប់មក លោកស្រីបានសុំឲ្យអ្នកចូលរួមសញ្ជឹងគិតពីវិធានការជាបន្តបន្ទាប់ ដែលប្រទេសកម្ពុជាបានធ្វើរួចមកហើយចាប់តាំងពីឆ្នាំ ១៩៧៩ មក ដែលវិធានការជាច្រើនត្រូវបានអ្នកខាងក្រៅមើលរំលង។ អ.វ.ត.ក មិនមែនត្រឹមតែជាការឆ្លើយតបមួយប៉ុណ្ណោះទេ វាក៏ជាកិច្ចខិតខំប្រឹងប្រែងសំខាន់បំផុត និងមានការគាំទ្រជាអន្តរជាតិផងដែរមកដល់សព្វថ្ងៃនេះ។ យុត្តិធម៌អន្តរកាលជានិច្ចកាលគឺផ្តោតអំពីដំណោះស្រាយជាក់ស្តែង និងជាដំណោះស្រាយអាចធ្វើទៅបានខាងនយោបាយ ហើយនៅក្នុងករណីរបស់ប្រទេសកម្ពុជា វាមានសារៈសំខាន់ក្នុងការចងចាំពីការលំបាកនានា ដែលបន្ត ដោយសារការបរាជ័យក្នុងកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ ១៩៩១ ដើម្បីដោះស្រាយចម្ងល់ខាងយុត្តិធម៌។ អ្នកចូលរួមត្រូវបានសុំឲ្យបញ្ចេញទស្សនៈអំពីយុត្តិធម៌អន្តរកាល ឬយុត្តិធម៌យេនឌ័រ ដែលពួកគេកំពុងធ្វើការដោះស្រាយនាពេលបច្ចុប្បន្ននេះ។

ចំណុចនានាអំពីយុត្តិធម៌អន្តរកាលដែលអ្នកចូលរួមបានផ្តល់៖

១. ការប្រាប់ និងការស្វែងរកការពិត

២. ការរៀបចំទុកឯកសារ/ការប្រមូលផ្តុំភស្តុតាង

៣. សំណូមពរ និងការស្តារនីតិសម្បទា

៤. ការគោរពសិទ្ធិមនុស្សតាមរយៈ (សិទ្ធិស្ត្រី ដោយរួមបញ្ចូលទាំងការប្រទូស្តកេរ្តិ៍ខ្មាស ប្រឆាំងនឹងការរើសអើង/សមភាពយេនឌ័រ និងយុត្តិធម៌ (តើនេះទាក់ទងនឹងយុត្តិធម៌អន្តរកាលដោយរបៀបណា?)

៥. យុត្តិធម៌ដែលស្តារមកវិញ

៦. ការគាំពារជនរងគ្រោះ

៧. សំណង

៨. ដំណើរការនីតិវិធីខាងឧក្រិដ្ឋកម្ម

៩. ជម្លោះប្រដាប់អាវុធនៅព្រំដែនថៃ

បន្ទាប់មក លោកស្រី Reiger បន្តទៅពិនិត្យលើទស្សនៈយល់ឃើញអំពីការយល់ដឹងអំពីយេនឌ័រ ដែលជាបឋមពាក់ព័ន្ធនឹងប្រទេសកម្ពុជាជាទូទៅ និងក្រោយមក ពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ តើមានទំនាក់ទំនងអ្វីរវាងទម្រង់នៃអំពើហិង្សាកាលពីអតីតកាល និងបច្ចុប្បន្នកាលដែរឬទេ? លោកស្រីបានធ្វើបទបង្ហាញមេរៀនជាច្រើន ដែលបានមកពីបទពិសោធន៍អន្តរជាតិអំពីសភាពនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ អំឡុងពេលជម្លោះ និងរបៀបជាច្រើនដែលជារឿយៗស្ត្រីត្រូវឆ្លងកាត់ ដូចជាអ្វីដែលបន្តរវាងទម្រង់នៃការរើសអើង និងអំពើហិង្សានៅពេលមុន និងនៅពេលក្រោយ។ បន្ទាប់មក លោកស្រីបានពិនិត្យមើលវិធីមួយចំនួន ដែលជាដំណើរការនៃយុត្តិធម៌អន្តរកាល ដូចជាការស្វែងរកការពិត និងសំណង ដែលត្រូវបានសម្របសម្រួលដើម្បីឲ្យឆ្លើយតបទៅនឹងតម្រូវការ និងការទាមទាររបស់ជនរងគ្រោះពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**តើត្រូវរួមបញ្ចូលការផ្តោតលើយេនឌ័រដោយរបៀបណា?**

**ធ្វើលំហាត់ (៣០ នាទី) និងរាយការណ៍មកវិញ**

លោកស្រី Caitlin បានសុំឲ្យអ្នកចូលរួមធ្វើការជាដៃគូ ដើម្បីស្វែងរកអំណះអំណាងតែរៀងៗខ្លួន ដើម្បីគាំទ្រវិធីសាស្ត្រពីរខុសគ្នា ក្នុងការដាក់បញ្ចូលបញ្ហាយេនឌ័រទៅក្នុងកម្មវិធីគម្រោង។ ចំណុចទីមួយគឺផ្តោតលើបទពិសោធន៍របស់ស្ត្រី និងចំណុចទីពីរគឺត្រូវពិនិត្យមើលបុព្វហេតុ ដែលជារចនាសម្ព័ន្ធទូលំទូលាយស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ (មនុស្សម្នាក់ដើរតួជា ក ហើយម្នាក់ទៀតដើរតួជា ខ)។ ពួកគេបានចំណាយពេល ៣០ នាទីពិភាក្សាគ្នាអំពីករណីនេះ ហើយមានការពិភាក្សាគ្នាជាច្រើនយ៉ាងរស់រវើក។ បន្ទាប់មក ក្រុមពិភាក្សា

នីមួយៗបានរាយការណ៍ត្រឡប់មកក្រុមទាំងមូលវិញ។ មនុស្សភាគច្រើនយល់ថា វិធីសាស្ត្រទាំងពីរមានចំណុចល្អតែរៀងៗខ្លួន ហើយជាទស្សនៈ ការរៀបចំកម្មវិធីនានាគួរតែដាក់បញ្ចូលសមាសធាតុទាំងពីរនេះទៅក្នុងការងាររបស់ខ្លួន។

## ៣.យុត្តិធម៌យេនឌ័រសម្រាប់ឧក្រិដ្ឋកម្មពីអតីតកាលក្នុងប្រទេសឥណ្ឌូនេស៊ី និងប្រទេសទីម័រខាងកើត




បន្ទាប់ពីអាហារថ្ងៃត្រង់រួច អ្នកចូលរួមសិក្ខាសាលាទាំងអស់បានស្តាប់បទបង្ហាញរបស់លោកស្រី Galuh Wandita ដែលធ្វើតាមរយៈកម្មវិធី Skype ពីប្រទេសឥណ្ឌូនេស៊ី។ លោកស្រី Galuh Wandita Soedjatmoko គឺជាអ្នកជំនាញមួយរូបខាងយេនឌ័រ និងយុត្តិធម៌អន្តរកាល ដែលជាអ្នកផ្តួចផ្តើមគំនិតលើកិច្ចការនេះក្នុងខេត្ត Aceh និង Papua ក៏ដូចជានៅកម្រិតថ្នាក់ជាតិមួយក្នុងប្រទេសឥណ្ឌូនេស៊ី និងប្រទេសទីម័រខាងកើត។ បទបង្ហាញរបស់លោកស្រីផ្តោតទាំងវិធីផ្លូវការ និងមិនផ្លូវការដែលសំឡេងស្ត្រីក្នុងប្រទេសទីម័រខាងកើត និងឥណ្ឌូនេស៊ីត្រូវបានគេរក្សាទុកជាឯកសារ ដែលជាផ្នែកមួយនៃកិច្ចខំប្រឹងប្រែងរកយុត្តិធម៌អន្តរកាល។

## ៤. ដំណើរឆ្ពោះទៅមុខនៃការយល់ដឹងអំពីយេនឌ័រ និងយុត្តិធម៌អន្តរកាលក្នុងប្រទេសកម្ពុជា

អ្នកចូលរួមទាំងអស់ត្រូវបានចែកជាក្រុមតូចៗ ដើម្បីស្វែងរកឲ្យកាន់តែលម្អិតនូវឱកាស និងយុទ្ធសាស្ត្រដែលអាចធ្វើទៅបានសម្រាប់ស្វែងរកយុត្តិធម៌យេនឌ័រ ចំពោះឧក្រិដ្ឋកម្មកាលពីអតីតកាលក្នុងប្រទេសកម្ពុជា។ ក្រុមនីមួយៗបានផ្តោតលើចំណុចខុសៗគ្នានៃសកម្មភាពយុត្តិធម៌អន្តរកាល ដែលកំពុងកើតឡើងនាពេលបច្ចុប្បន្ន។



សំណួរសម្រាប់ក្រុមនីមួយៗ

| | សំណួរ | ចម្លើយ |
|---|---|---|
| **ក្រុម ១ សំណាង/ការគាំពារជនរងគ្រោះ** | សំណួរ១<br>តើមានគម្រោងយុត្តិធម៌អន្តរកាលដែលមាននៅពេលបច្ចុប្បន្ននេះ ឬនៅពេលអនាគត ដែលអាចផ្តោតលើបញ្ហាយេនឌ័រដែរឬទេ? | បាទ/ចាស ក្រុមផ្សព្វផ្សាយស្តីពីសំណាង និងយេនឌ័រ |
| | សំណួរ២<br>តើកម្មវិធីអ្វីដែលគេអាចនឹងត្រូវរៀបចំបន្ថែមទៀត? | យេនឌ័រពាក់ព័ន្ធនឹងជនរងគ្រោះខ្មែរក្រហម ដែលក្រុមត្រូវជួយខ្លួនឯង |
| | សំណួរ៣<br>តើបញ្ហាប្រឈមធំបំផុតមានអ្វីខ្លះ? | មូលនិធិទ្រទ្រង់ និងការគាំទ្រផ្នែកបច្ចេកទេស |
| | សំណួរ៤<br>តើគោលដៅអ្វីដែលអ្នកនឹងកំណត់? តើអ្នកនឹងវាស់ស្ទង់ការរីកចម្រើនដែលឈានទៅសម្រេចគោលដៅនោះដោយរបៀបណា? | ការវាយតម្លៃដោយភាគីខាងក្រៅចំពោះប្រសិទ្ធភាព និងផលប៉ះពាល់ |
| | សំណួរ៥<br>តើអ្នកនឹងសម្របសម្រួលជាមួយនឹងស្ថាប័នផ្សេងទៀតដែលធ្វើការពាក់ព័ន្ធនឹងយុត្តិធម៌អន្តរកាល ដោយ | សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងការផ្សព្វផ្សាយ |

| | | |
|---|---|---|
| | របៀបណា? | |
| **ក្រុម២**<br>**ការស្វែង រកការពិត/ការរក្សាទុកឯកសារ** | សំណួរ១<br>តើមានគម្រោងយុត្តិធម៌អន្តរកាលដែលមាននៅពេលបច្ចុប្បន្ននេះ ឬនៅពេលអនាគត ដែលអាចផ្តោតលើបញ្ហាយេនឌ័រដែរឬទេ? | ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស (CDP)៖<br>- ភាពយន្តស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (បានជួយដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើន)<br>-ការស្តាប់ការនិយាយរបស់ស្ត្រី និងរបាយការណ៍ជាច្រើន<br>(ការចាក់បញ្ចាំងពីសវនាការសម្រាប់ការអប់រំ)<br>-ការស្រាវជ្រាវអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសម័យខ្មែរក្រហម<br>-កូនសៀវភៅ(រឿងរ៉ាវរបស់ជនរងគ្រោះ)<br>មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)<br>-កម្មវិធីវិទ្យុអំពីរឿងរ៉ាវរបស់ស្ត្រីក្នុងអំឡុងសម័យខ្មែរក្រហម |
| | សំណួរ២<br>តើកម្មវិធីអ្វីដែលគេអាចនឹងត្រូវរៀបចំបន្ថែមទៀត? | **ការផ្លាស់ប្តូរជាវិជ្ជមានរបស់កម្ពុជា (PCC)**<br>-រួមបញ្ចូលបញ្ហាយុត្តិធម៌អន្តរកាលក្នុងកម្មវិធីបច្ចុប្បន្ន<br>ក.ផ្តល់សំឡេងដល់ស្ត្រី<br>ខ.ស្តាប់នូវការនិយាយចេញមកក្រៅរបស់ស្ត្រីឲ្យបានច្រើន<br>គ.សិទ្ធិស្ត្រី និងការគាំពារខាងយេនឌ័រនៅកម្រិតអន្តរជាតិ និងកម្រិតជាតិជាមួយសមាគមជាតិអាស៊ីអាគ្នេយ៍ (ASEAN) (វីដេអូ |

| | | |
|---|---|---|
| | | និងករណីសិក្សា)<br>**បន្ទាយស្រី** (BS)<br>-ឯកសារប្រវត្តិសាស្ត្រអំពីអំពើហិង្សាលើជនរងគ្រោះអំឡុងសម័យខ្មែរក្រហម និងវិធីដែលរឿងនេះអាចនៅជិតដាមអំពើហិង្សាក្នុងគ្រួសាររហូតនិងក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស(CDP)<br>- ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស(CDP)៖<br>១.ការស្តាប់ការនិយាយរបស់ស្ត្រីឲ្យកាន់តែទូលំទូលាយ (ច្រើនជាងពីមុន)<br>២.ឯកសារចិត្តសាស្ត្រ/ការគាំទ្រ<br>៣.ការប្រាប់ការពិតនៅកម្រិតសហគមន៍ ជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌(TPO)<br>៤.ការរក្សាទុកឯកសារសំណុំរឿងពីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រប្រឆាំងនឹងបុរស |
| | សំណួរ៣<br>តើបញ្ហាប្រឈមធំបំផុតមានអ្វីខ្លះ? | -មូលនិធិ<br>-ធ្វើឲ្យជនរងគ្រោះ (បុរស និងស្ត្រី) មានភាពងាយស្រួលក្នុងការនិយាយចេញមកក្រៅ<br>-ការទប់ទល់នឹងផ្នត់គំនិតទូទៅ<br>-ជម្នះនឹងការរើសអើងពីសង្គម<br>-ការធ្វើឲ្យរដ្ឋាភិបាលចូលរួមធ្វើការជាមួយ<br>-ផ្តល់សុវត្ថិភាពដល់ជនរងគ្រោះដែលនិយាយចេញប្រឆាំងនឹងមនុស្សដែលនៅរស់រានមានជីវិត<br>-វាស់ស្ទង់ប្រសិទ្ធភាព |
| | សំណួរ៤ | -ការស្តាប់ការនិយាយរបស់ស្ត្រី |

| | | |
|---|---|---|
| | តើគោលដៅអ្វីដែលអ្នកនឹងកំណត់? តើអ្នកនឹងវាស់ស្ទង់ការរីកចម្រើនដែលឈានទៅសម្រេចគោលដៅនោះដោយរបៀបណា? | -គោលបំណង៖ បង្កើនឥទ្ធិពល<br>-វិធានការ៖ ចំនួនអ្នកធ្វើសក្ខីកម្ម និងអ្នកចូលរួម<br>• កម្មវិធីវិទ្យុ<br>-វាស់ចំណេះដឹងរបស់អ្នកស្តាប់ និងអ្នកទូរស័ព្ទតាមរយៈការស្ទាបស្ទង់មតិ<br>-គោលបំណង៖ បង្កើន<br>• ឯកសារបន្ទាយស្រី<br>ទំនាក់ទំនងរវាងអំពើហិង្សាអំឡុងសម័យខ្មែរក្រហម និងការស្ទាបស្ទង់មតិអំពើហិង្សាក្នុងគ្រួសារ នាពេលបច្ចុប្បន្នដើម្បីកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ |
| | សំណួរ៥<br>តើអ្នកនឹងសម្របសម្រួលជាមួយនឹងស្ថាប័នផ្សេងទៀតដែលធ្វើការពាក់ព័ន្ធនឹងយុត្តិធម៌អន្តរកាល ដោយរបៀបណា? | • ផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលក្នុងការគាំទ្រដល់ការស្វែងរកការពិត និងការរក្សាទុកឯកសារពីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ<br>• សម្របសម្រួលជាមួយអង្គការក្នុង និងក្រៅប្រទេស<br>• ចងក្រងឯកសារដែលឆ្លុះបញ្ចាំងទាំងការអនុវត្តល្អ និងការអនុវត្តមិនល្អ ដើម្បីរៀបចំយុទ្ធសាស្ត្រគម្រោងដើម្បីជៀសវាងកំហុស និងការបរាជ័យ |
| **ក្រុម ៣**<br>**ការពិភាក្សាជាសាធារណៈ/ការផ្សព្វផ្សាយ/ការ** | សំណួរ១<br>តើមានគម្រោងយុត្តិធម៌អន្តរកាលដែលមាននៅពេលបច្ចុប្បន្ននេះ ឬនៅពេល | គម្រោងរបស់ TT៖<br>ដើម្បីរួមបញ្ចូលការបញ្ជ្រាបយេនឌ័រ (គម្រោងបច្ចុប្បន្ន)<br>• ការសន្ទនារវាងមនុស្សក្នុងអន្តរជំនាន់ |

| | | |
|---|---|---|
| **អប់រំ** | អនាគត ដែលអាចផ្តោតលើបញ្ហាយេនឌ័រដែរឬទេ? | • វេទិកាយុវជន មជ្ឈមណ្ឌលរៀនសូត្រ<br>• កម្មវិធីបណ្តុះបណ្តាល<br>• ក្រុមផ្តោតលើយេនឌ័រ<br>• ជនបង្គោលលើយេនឌ័រនៅវិទ្យាស្ថាន<br>• ជនរងគ្រោះខាងផ្លូវភេទ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រចូលរួមក្នុងយុត្តិធម៌ និងស្តារសិទ្ធិរបស់ពួកគេ<br>• ការយល់ដឹងលើកឡើងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ/វិទ្យុ<br>• ការចូលរួមឲ្យបានទូលំទូលាយពីសាធារណជន/ ភាពខុសគ្នាខាងយេនឌ័រដើម្បីពិចារណា |
| | សំណួរ២<br>តើកម្មវិធីអ្វីដែលគេអាចនឹងត្រូវរៀបចំបន្ថែមទៀត? | -អនុញ្ញាតឲ្យស្ត្រី និងកុមារមកទស្សនាតុលាការ/ស្តាប់សវនាការ<br>-រួមបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងយេនឌ័រចូលក្នុងតុលាការ IECs, info, កម្មវិធីនយោបាយ<br>ការបោះពុម្ពផ្សាយដែលអាចធ្វើទៅបានឲ្យកាន់តែច្រើន<br>- បណ្តុះបណ្តាលបុគ្គលិកក្នុងស្ថាប័ន/យេនឌ័រ/កម្មវិធី<br>- ការបន្ថែមបញ្ហាពាក់ព័ន្ធនឹងយេនឌ័រឲ្យបានច្រើនក្នុងកម្មវិធីសម្រាប់ការពិភាក្សាជាសាធារណៈ។<br>-បុរសភេទក៏ជាគោលដៅសម្រាប់ការពិចារណាទាំងអស់ក្នុងគម្រោងនានា |

| | | |
|---|---|---|
| | | |
| | សំណួរ៣<br>តើបញ្ហាប្រឈមធំបំផុតមានអ្វីខ្លះ? | -អាណត្តិតុលាការ/នីតិវិធីតុលាការ<br>-ប្រតិកម្មឆ្លើយតប និងធនធាន<br>-គោលនយោបាយស្ថាប័ន/ ការរួមបញ្ចូលបុគ្គលិក |
| | សំណួរ៤<br>តើគោលដៅអ្វីដែលអ្នកនឹងកំណត់? តើអ្នកនឹងវាស់ស្ទង់ការរីកចម្រើនដែលឈានទៅសម្រេចគោលដៅនោះដោយរបៀបណា? | ចាប់ផ្តើមកសាងសមត្ថភាព និងផ្តល់អំណាចដល់ក្រុមយេនឌ័រទៅក្នុងការសិក្សាដោយការបណ្តុះបណ្តាលពីលទ្ធផល និងការស្ទង់មតិ |
| | សំណួរ៥<br>តើអ្នកនឹងសម្របសម្រួលជាមួយនឹងស្ថាប័នផ្សេងទៀតដែលធ្វើការពាក់ព័ន្ធនឹងយុត្តិធម៌អន្តរកាល ដោយរបៀបណា? | បណ្តាញយេនឌ័រ/បណ្តាញជនបង្គោលខាងយេនឌ័រ |
| **ក្រុម ៤**<br>**ការរំឭក** | សំណួរ១<br>តើមានគម្រោងយុត្តិធម៌អន្តរកាលដែលមាននៅពេលបច្ចុប្បន្ននេះ ឬនៅពេលអនាគត ដែលអាចផ្តោតលើបញ្ហាយេនឌ័រដែរឬទេ? | -បាទ/ចាស បង្កើតក្រុមយុទ្ធជនរួមមានស្ត្រី និងបុរសដើម្បីបង្ហាញឲ្យច្បាស់នូវការរំឭកក្នុងសហគមន៍របស់ពួកគេ<br>-ប្រមូលព័ត៌មានទាំងអស់ពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងចងក្រងឯកសារសម្រាប់ការរំឭក<br>-ស្ថាបនាឡើងវិញ និងជួសជុលចេតិយសម្រាប់ការរំឭក (មិនផ្តោតតែលើស្ត្រី) |
| | សំណួរ២ | គួរកសាងចេតិយ ដែលយើងកំពុងផាត់ពណ៌លើ |

| | | |
|---|---|---|
| | តើកម្មវិធីអ្វីដែលគេអាចនឹងត្រូវរៀបចំបន្ថែមទៀត? | អំពើហិង្សាខាងយេនឌ័រ (ការរៀបការដោយបង្ខំ) |
| | សំណួរ៣<br>តើបញ្ហាប្រឈមធំបំផុតមានអ្វីខ្លះ? | -ចំណេះដឹងខាងយេនឌ័រក្នុងយុត្តិធម៌អន្តរកាល (GTJ)<br>-បញ្ហាថវិកា<br>-សកម្មភាពផ្សព្វផ្សាយផ្តោតលើយេនឌ័រក្នុងយុត្តិធម៌ អន្តរកាល (GTJ) ក្នុងសហគមន៍មិនបានទូលំទូលាយ |
| | សំណួរ៤<br>តើគោលដៅអ្វីដែលអ្នកនឹងកំណត់? តើអ្នកនឹងវាស់ស្ទង់ការរីកចម្រើនដែលឈានទៅសម្រេចគោលដៅនោះដោយរបៀបណា? | -គម្រោងនៃការរំឭកគួរផ្តោតលើយុត្តិធម៌អន្តរកាល (GTJ)<br>-វិធានការ៖ តើគម្រោងចំនួនប៉ុន្មានពាក់ព័ន្ធនឹងយុត្តិធម៌អន្តរកាល (GTJ)? |
| | សំណួរ៥<br>តើអ្នកនឹងសម្របសម្រួលជាមួយនឹងស្ថាប័នផ្សេងទៀតដែលធ្វើការពាក់ព័ន្ធនឹងយុត្តិធម៌អន្តរកាល ដោយរបៀបណា? | ការរំឭក (ការប្រាប់ការពិត សំណាង យុត្តិធម៌ ការផ្សះផ្សា ការរក្សាទុកឯកសារ) |
| **ក្រុម ៥** | សំណួរ១ | គម្រោងដែលកើតនាពេលបច្ចុប្បន្ន៖ |

| | | |
|---|---|---|
| **កំណែទម្រង់ច្បាប់/ការមិនកើតឡើងម្តងទៀត** | តើមានគម្រោងយុត្តិធម៌អន្តរកាលដែលមាននៅពេលបច្ចុប្បន្ននេះ ឬនៅពេលអនាគត ដែលអាចផ្តោតលើបញ្ហាយេនឌ័រដែរឬទេ? | ការពិភាក្សាដេញដោលដំណើរការយេនឌ័រ<br>- កំណែទម្រង់យុត្តិធម៌ + ច្បាប់→ចំណែកថវិកាខាងនយោបាយ<br>- ច្បាប់/កេរតំណែល (OCHCT) → ពិភាក្សាតុមូលស្តីពីការកាត់ទោសបទរំលោភ + និទណ្ឌភាព<br>- ការតាមដានសវនាការ (CCHR+AIJR) →ស្ថិតក្រោមការពិភាក្សា<br>- ការវិភាគអំពីសិទ្ធិមនុស្ស→ផលវិបាកសម្រាប់ស្ត្រីដែលរងអំពើហិង្សាកាលពីអតីតកាលស្ថានភាពបច្ចុប្បន្ន |
| | សំណួរ២<br>តើកម្មវិធីអ្វីដែលគេអាចនឹងត្រូវរៀបចំបន្ថែមទៀត? | លើកបង្ហាញពីស្ថានភាពយេនឌ័រក្នុងកម្មវិធីដែលមានតាមរយៈការបញ្ជ្រាបយេនឌ័រ<br>→ធ្វើឲ្យគោលនយោបាយយេនឌ័រផ្នែកខាងក្នុងបានប្រសើរឡើង<br>→រួមបញ្ចូលបទពិសោធន៍របស់ស្ត្រីក្នុងប្រធានបទជជែកពិភាក្សានីមួយៗ<br>→រួមបញ្ចូលចំណុចលក្ខណៈវិនិច្ឆ័យសម្រាប់ការតាមដានសវនាការស្តីពីការប្រព្រឹត្តរបស់ជនជាប់ចោទ<br>ជាស្ត្រី/ជនរងគ្រោះ |
| | សំណួរ៣<br>តើបញ្ហាប្រឈមធំបំផុតមានអ្វីខ្លះ? | - ចំណេះដឹង + ការភ្ញាក់រឭក + ការប្រតិបត្តិជាក់ស្តែងនឹងបង្កើតឲ្យកំណែទម្រង់ច្បាប់ស្តីចំពោះការយល់ដឹងអំពីយេនឌ័រ |

| | | |
|---|---|---|
| | | -ការពិភាក្សាដោយកំណត់ពីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅអ.វ.ត.ក (គេរតំណែលគួរតែរួមបញ្ចូលកំណត់ត្រាដែលមានលក្ខណៈប្រវត្តិសាស្ត្រ) |
| | សំណួរ៤<br>តើគោលដៅអ្វីដែលអ្នកនឹងកំណត់? តើអ្នកនឹងវាស់ស្ទង់ការរីកចម្រើនដែលឈានទៅសម្រេចគោលដៅនោះដោយរបៀបណា? | ឧទាហរណ៍សម្រាប់គេរតំណែល<br>- កំណត់ត្រាដែលមានលក្ខណៈប្រវត្តិសាស្ត្រមិនបានបញ្ចូលនូវបទពិសោធន៍ជាក់លាក់របស់ស្ត្រីឡើយ។<br>-គេរតំណែលយុត្តាធិការមិនគួរអនុញ្ញាតឲ្យមានការរួចផុតពីការទទួលទោស ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនោះទេ។<br>-គេរតំណែលនីតិវិធីគួរតែលើកបង្ហាញពីសមភាពយេនឌ័រ។<br>-សំណាងពិនិត្យពិចារណាលើតម្រូវការរបស់ស្ត្រី<br>-ការគាំពារសាក្សី |
| | សំណួរ៥<br>តើអ្នកនឹងសម្របសម្រួលជាមួយនឹងស្ថាប័នផ្សេងទៀតដែលធ្វើការពាក់ព័ន្ធនឹងយុត្តិធម៌អន្តរកាល ដោយរបៀបណា? | គ្មាន |

## ៥. ការវាយតម្លៃលើសិក្ខាសាលា

បន្ទាប់ពីការសម្រាកអាហារសម្រន់មក អ្នកចូលរួមទាំងអស់ត្រូវបានគេស្នើឲ្យបំពេញបែបបទនៃការវាយតម្លៃដើម្បីស្វែងយល់អំពីរបៀបដែលអ្នកចូលរួមទាំងអស់បានបង្កើនចំណេះដឹងរបស់គេពីការយល់ដឹងខាងយេនឌ័រ និងយុត្តិធម៌អន្តរកាល។

| **អង្គការ** | **សំណួរ១ តើអ្នកយល់ថាសិក្ខាសាលាមានសារៈសំខាន់ដែរឬទេ?** | **សំណួរ២ តើអ្នកបានដឹងអ្វីដែលថ្មីដែរឬទេ?** | **សំណួរ៣ តើវគ្គបណ្តុះបណ្តាលអាចត្រូវធ្វើឲ្យកាន់តែប្រសើរដោយរបៀបណា?** | **សំណួរ៤ សូមលើកសំណូមពរសម្រាប់ការបណ្តុះបណ្តាលបែបនេះទៅថ្ងៃក្រោយ** | **សំណួរ៥ តើមានយោបល់អ្វីផ្សេងទៀតទេ?** |
|---|---|---|---|---|---|
| អ.វ.ត.ក | -ខ្ញុំដឹងពីព័ត៌មានថ្មី “តើអ្វីទៅជាយុត្តិធម៌អន្តរកាល និងយេនឌ័រ”។ វាពិតជាមានសារៈសំខាន់សម្រាប់ការស្វែងរកយុត្តិធម៌ក្នុងសង្គម និងប្រទេស | វិធីបួនយ៉ាងសម្រាប់ផ្តល់យុត្តិធម៌៖<br>១. ការផ្តល់សំណង និងការគាំពារជនរងគ្រោះ<br>២. ការដឹងឮ<br>៣.ការស្វែងរកការពិត<br>៤.យុត្តិធម៌ | សិក្ខាសាលានេះមានសារៈសំខាន់បំផុតសម្រាប់ខ្ញុំដោយសារខ្ញុំធ្វើការយ៉ាងជិតស្និទ្ធជាមួយជនរងគ្រោះនិងអំពីយេនឌ័រ | | |
| | បាទ/ចាស | -ទទួលបានទស្សនៈវិស័យទូលំទូលាយចំពោះ អ.វ.ត.ក | -អាចល្អប្រសើរប្រសិនបើអ្នកចូលរួមអង្គុយចុះនៅតុមូលស្វែងរក | | អរគុណអ្នកសម្រាប់សិក្ខាសាលាប្រកប |

| | | | | | |
|---|---|---|---|---|---|
| | | ដែលផ្តោតលើយុត្តិធម៌អន្តរកាល<br>-ស្ថិតិនៃការបែងចែកភេទរបស់ជនរងគ្រោះ<br>-ចំណុចនៃកិច្ចព្រមព្រៀងសន្តិភាព | ចំណុចផ្តើមដើម្បីមានកិច្ចពិភាក្សាគ្នាពេញមួយថ្ងៃ | | ដោយភាពជោគជ័យ |
| Banteays rei | បាទ/ចាស ខ្ញុំបានរៀនសូត្រចំណេះដឹងជាច្រើន។ អ្នកធ្វើបទបង្ហាញគឺពិតជាល្អ ពិតជាច្បាស់។ បទបង្ហាញងាយយល់។ អ្នកចូលរួម មានភាពងាយស្រួលក្នុងផ្តល់មតិ ឬសួរសំណួរ។ | បាទ/ចាស ខ្ញុំពិតជាមិនយល់អ្វីឡើយអំពីយុត្តិធម៌អន្តរកាល មុនមកចូលរួមក្នុងសិក្ខាសាលានេះ។ ខ្ញុំចង់ដឹងឲ្យកាន់តែច្រើនអំពីហិង្សាផ្លូវភេទ និងហិង្សាទាក់ទងនឹងយេនឌ័រ អំឡុងសម័យខ្មែរក្រហម | គ្មាន | គ្មាន | គ្មាន |
| | វាមានសារប្រ | - | វាប្រសើរណាស់ | វាល្អចំពោះអ្នក | - |

| | | | | | |
|---|---|---|---|---|---|
| | យោជន៍សម្រាប់ខ្ញុំបង្កើនចំណេះដឹងអំពីការយល់ដឹងខាងយេនឌ័រ និងពីអត្ថន័យនៃយុត្តិធម៌អន្តរកាល | ការយល់ដឹងអំពីយេនឌ័រ<br>-យុត្តិធម៌អន្តរកាល<br>-គោលដៅនៃការយល់ដឹងអំពីយេនឌ័រ និងយុត្តិធម៌អន្តរកាល | ព្រោះវាទាក់ទងនឹងយុត្តិធម៌អន្តរកាល និងគោលដៅនៃការយល់ដឹងពីយេនឌ័រ | ចូលរួមដើម្បីដឹងពីយុត្តិធម៌អន្តរកាល និងធ្វើការផ្តោតទៅលើចំណុចសំខាន់នៃយុត្តិធម៌ | ខ្ញុំចង់បានសិក្ខាសាលាបែបនេះឲ្យបានលើសពីមួយលើកនេះទៀត។<br>-វាមានពេលខ្លីក្នុងការសិក្សា |
| Not mention org. | -វាមានសារៈសំខាន់ដោយអ្នកសម្របសម្រួលមានការផ្តោតច្រើនទៅលើយេនឌ័រ និងយុត្តិធម៌អន្តរកាល។<br>-វាក៏ជាចំណុចល្អផងដែរ ដែលសិក្ខាសាលាបានផ្តល់ចំណេះដឹងសង្ខេបស្តីពីអត្ថន័យ របស់យេនឌ័រ | -យុត្តិធម៌អន្តរកាល៖ ការពិត, យុត្តិធម៌, សំណង, ការមិនកើតឡើងម្តងទៀត | -ប្រើប្រាស់វិធីសាស្ត្រខុសគ្នា<br>-ការផ្តោតច្រើនទៅលើយេនឌ័រ យុត្តិធម៌ អន្តរកាល | -មិនចាំបាច់ពិភាក្សាច្រើនលើអត្ថន័យយេនឌ័រទេ។ វាមិនមែនជាបញ្ហា ឬពាក្យថ្មីនោះទេ។ អង្គការ និងភ្នាក់ងាររដ្ឋាភិបាលជាច្រើនបានធ្វើការលើបញ្ហានេះជាយូរមកហើយ។<br>-គប្បីផ្តល់បទពិសោធន៍ឲ្យបានច្រើនស្តីពីយេនឌ័រ | -គប្បីផ្តល់ការអនុវត្តច្រើនទៅលើយុទ្ធសាស្ត្រខាងយេនឌ័រ និងយុត្តិធម៌អន្តរកាលក្នុងការរៀបចំគម្រោង |

| | | | | | |
|---|---|---|---|---|---|
| | | | | និងយុត្តិធម៌អន្តរកាល | |
| Not mention org. | បាទ/ចាស | -យុត្តិធម៌អន្តរកាល<br>-ការយល់ដឹងពីយេនឌ័រ | លើសពីមួយថ្ងៃ (គួរតែពីរថ្ងៃ) | គ្មាន | គ្មាន |
| TPO | បាទ/ចាស ខ្ញុំពិតជាបានយល់ដឹងពីយុត្តិ ធម៌អន្តរកាល ប៉ុន្តែអ្វីដែលថ្មីគឺយេនឌ័រពាក់ព័ន្ធនឹងយុត្តិធម៌អន្តរកាល ហើយខ្ញុំយល់ថាវាគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់។ | -យេនឌ័រ និងយុត្តិធម៌អន្តរកាល<br>-ការប្រជុំយប្រធានមួយចំនួនដែលយើងគួរគិត ខណៈពេលអនុវត្តយេនឌ័រយុត្តិធម៌អន្តរកាល | -ត្រូវការពេលវេលាច្រើនសម្រាប់ពិភាក្សា ទាំងក្រុមធំ និងក្រុមតូច | គ្មាន | គ្មាន |
| ADHOC | -ផ្តល់បទពិសោធន៍ ច្រើនទាក់ទងនឹងយុត្តិធម៌យេនឌ័រ និងការយល់ដឹង<br>-បានទទួលចំណេះដឹងច្រើនអំពីវិធីធ្វើឲ្យយេនឌ័រដំណើរ | -ចំណេះដឹងអំពីទស្សនៈនៃការយល់ដឹងពីយេនឌ័រ<br>-បញ្ហាបច្ចុប្បន្នរបស់យេនឌ័រក្នុងសង្គម និងគ្រួសារ | -ផ្តល់ឱកាសឲ្យបានច្រើនដល់អ្នកចូលរួមក្នុងការបញ្ចេញគំនិត<br>-ការចែករំលែកបទពិសោធន៍ក្នុងចំណោមអ្នកចូលរួម និងការណែនាំ | -យន្តការនៃបង្កើតចន្លោះសម្រាប់សមភាពយេនឌ័រក្នុងសង្គម<br>-វិធីដោះស្រាយស្ថានភាពអាក្រក់រវាង | -គប្បីលើកតម្កើង/បង្កើតឲ្យមានសមភាពយេនឌ័រ<br>-ការពិភាក្សាជា |

| | | | | | |
|---|---|---|---|---|---|
| | ការក្នុងសង្គម និងគ្រួសារ -បទពិសោធន៍ និង ទស្សនវិស័យ ស្តីពី បញ្ហាយេនឌ័រ) | | បង្ហាត់ បង្ហាញ របស់អ្នកជំនាញ | យុត្តិធម៌ និងការ ផ្សះផ្សាក្នុងផ្នត់ គំនិតនៃប្រ ទេសកម្ពុជា | ក្រុមច្រើន ជាជាងការ ពិភាក្សា ដោយ អ្នកជំនាញ |
| | វាគឺសំខាន់ខ្លាំង ណាស់ | ដឹងអំពីយេនឌ័រ និងយុត្តិធម៌អន្តរ កាល | ការធ្វើបទបង្ហាញ ដោយបច្ចេកវិទ្យា ខ្ពស់ | ខ្ញុំយល់ថាវា មានពេលខ្លី សម្រាប់ការ បណ្តុះបណ្តាល នេះ | ពិបាកយល់ និងពិបាក ពិភាក្សាពី សំណួរ |
| AIJI | បាទ/ចាស សិក្ខា សាលានេះផ្តល់ ចំណេះដឹងដល់ខ្ញុំ ច្រើនដែលមាន សារប្រយោជន៍ សម្រាប់តាមដាន សវនាការក្នុង អ.វ.ត.ក ពាក់ព័ន្ធ នឹងបញ្ហាយេនឌ័រ ដែលអាចជាសិទ្ធិ មួយអំឡុងពេល ដំណើរការនីតិវិធី | បាទ/ចាស ព័ត៌មានពីអំពើ ហិង្សាពាក់ព័ន្ធ នឹងយេនឌ័រក្នុង ប្រទេសមួយចំនួ ន ដែលមាន អ្នកចូលរួម មកពី ប្រទេសក្នុង តំបន់ អាស៊ីអា គ្នេយ៍ ជាកន្លែង ដែលថ្មីសម្រាប់ ខ្ញុំ និងមានមូល ដ្ឋានចំនួនប្រាំ សម្រាប់ | ទេ | ទេ | ទេ |

| | | | | | |
|---|---|---|---|---|---|
| | | ការប្រៀបធៀបគ្នា | | | |
| | មិនមានប្រយោជន៍ដោយផ្ទាល់សម្រាប់អង្គការរបស់ខ្ញុំទេ ប៉ុន្តែជាទូទៅខ្ញុំយល់ថាវាគួរ ចាប់អារម្មណ៍ខ្លាំងណាស់ | បាទ/ចាស ទោះបីខ្ញុំ មានចំណេះដឹងខ្លះពីយុត្តិធម៌អន្តរកាល ប៉ុន្តែមិនដែលបានពិភាក្សាប្រធានបទឲ្យបានទូលំទូលាយទេ | គ្មាន | គ្មាន | គួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ |
| Not mention org. | វាសំខាន់ខ្លាំងណាស់ | ខ្ញុំរៀនចេះពាក្យការយល់ដឹងពីយេនឌ័រ អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្រោយពេលមានជម្លោះ តើអ្វីទៅជាយុត្តិធម៌អន្តរកាល? | -ត្រូវការការបកស្រាយបន្ថែមពីពាក្យគន្លឹះពាក់ព័ន្ធនឹងយេនឌ័រ | -គប្បីរៀបចំសិក្ខាសាលាបែបនេះឲ្យបានច្រើនព្រោះនេះជាប្រធានបទពិបាកយល់ | -ប្រើសំណួរគំរូ |
| WESU | សិក្ខាសាលានេះសំខាន់ខ្លាំងណាស់ព្រោះ វាមានសង្គមស៊ីវិលច្រើនចូលរួម | ខ្ញុំបានយល់ដឹងច្រើនអំពីដំណើរការនីតិវិធី អ.វ.ត.កទាក់ទងនឹងយេនឌ័រ | សិក្ខាសាលានេះល្អខ្លាំងណាស់ដែលយើងបង្ហាញពីប្រទេសទីម័រខាងកើត | សិក្ខាសាលានេះគួរតែអញ្ជើញអង្គការក្រៅរដ្ឋាភិបាលដែលកំពុងធ្វើការពាក់ព័ន្ធ | គួរតែជំរុញឲ្យមានការពិភាក្សា |

| | | | | | |
|---|---|---|---|---|---|
| | ហើយពួកគេ ធ្វើការយ៉ាងជិតស្និទ្ធលើបញ្ហានឹងយេនឌ័រដែលយើងជួបរៀងរាល់ថ្ងៃ | និងការធ្វើបទបង្ហាញរូបភាពអំពីប្រទេសទីម័រខាងកើត | តាមកម្មវិធី Skype | នឹងបញ្ហានេះឲ្យចូលរួមបានច្រើនជាងនេះ | |
| CHRAC | ខ្ញុំយល់ថាសិក្ខាសាលា នេះផ្តល់ព័ត៌មានដែលមានសារៈសំខាន់ខ្លាំងជាច្រើន និងត្រូវបានសម្របសម្រួលឲ្យមានការពិភាក្សាប្រកបដោយការរីកចម្រើនរវាងអង្គការក្រៅរដ្ឋាភិបាល | ខ្ញុំទទួលបានការយល់ដឹងប្រសើរពីយុត្តិធម៌អន្តរកាលជាពិសេសពាក់ព័ន្ធទៅនឹងភាពដាច់ដោយឡែកពីគ្នា ចំពោះស្ថានភាពនីមួយៗ | គ្មាន | គ្មាន | សិក្ខាសាលានេះល្អប្រសើរណាស់ អរគុណ |
| TPO | វាមានប្រយោជន៍សម្រាប់គម្រោងរបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ | ចេះដឹងអំពីបទពិសោធន៍យេនឌ័រពីយុត្តិធម៌អន្តរកាល និងប្រទេសទីម័រព្រមទាំងប្រទេសឥណ្ឌូនេស៊ី<br>- | រៀបចំបានល្អទាំងការអញ្ជើញភ្ញៀវ ទាំងការផ្តល់ព័ត៌មាន | ខ្ញុំចង់ផ្តល់មតិលើការរៀបចំពេលវេលាពិសេសចំពោះការសម្រាកអាហារសម្រន់និងពេលអាហារថ្ងៃត្រង់ | គ្មាន |

| | | | | | |
|---|---|---|---|---|---|
| | | ដើម្បីយល់ដឹងពីនិយមន័យនៃយុត្តិធម៌អន្តរកាល | | | |
| YFP | វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ខ្ញុំ | -យុត្តិធម៌អន្តរកាលយេនឌ័រ<br>-បទពិសោធន៍តុលាការរបស់ប្រទេសទីម័រខាងកើត | វាបានជួយខ្ញុំឲ្យផ្តួចផ្តើមគំនិតថ្មីដើម្បីរួមបញ្ចូលយុត្តិធម៌អន្តរការក្នុងគម្រោងរបស់ខ្ញុំ | ផ្តល់ឯកសារច្រើនពាក់ព័ន្ធនឹងប្រធានបទនេះ | វាមានពេលខ្លីសម្រាប់ការបណ្តុះបណ្តាលនេះ ខ្ញុំចង់ឲ្យមានការធ្វើបែបនេះ ២ ឬ៣ ដងទៀតនៅលើកក្រោយ។<br>-ចែករំលែកការវិភាគរឿងក្តីរបស់ប្រទេសផ្សេងទៀតអំពីប្រទេសអាហ្វ្រិចខាងត្បូង ។ល។ |
| | បាទ/ចាស សំខាន់ខ្លាំងណាស់ | តើកិច្ចខិតខំប្រឹងប្រែងអ្វីដែលប្រ | ការងារតាមក្រុមគួរមានរយៈពេលយូរ | គួរព្យាយាមអញ្ជើញបុគ្គលិក | |

| | | | | | |
|---|---|---|---|---|---|
| | ខ្ញុំបានទទួលគំនិតល្អៗដើម្បីទៅអប់រំអង្គការក្រៅរដ្ឋាភិបាលរបស់ខ្ញុំស្តីពីវិធីដើម្បីធ្វើឲ្យប្រសើរ និងបញ្ជ្រាបការយល់ដឹងពីយេនឌ័រពិសេស នៅអំឡុងវគ្គចុងក្រោយក្នុងក្រុមតូចៗ | ទេសផ្សេងៗបានធ្វើដើម្បីនាំយេនឌ័រ ចូលទៅក្នុងដំណើរការយុត្តិធម៌អន្តរកាល | និងធ្វើឲ្យបានលទ្ធផលជាក់ស្តែងជាពិសេសសម្រាប់ការពិភាក្សាដេញដោល (ដើរតួក្រុមក និងខ) នៅពេលព្រឹក | ផ្សេងទៀតផងដែរ មិនមែនត្រឹមតែប្រធានអង្គការក្រៅរដ្ឋាភិបាលនោះទេ។ ផ្តល់ព័ត៌មានឲ្យបានច្រើនស្តីពីយេនឌ័រដែលបញ្ជាក់ច្បាស់ក្នុងបរិបទប្រទេសកម្ពុជា។ តួនាទីយេនឌ័រមានចំណុចចាប់ផ្តើមសម្រាប់ការផ្លាស់ប្តូរ ។ល។ | |
| PCC | វាមានភាពចាំបាច់សម្រាប់ខ្ញុំ និងអង្គការ របស់ខ្ញុំ | ការរៀនសូត្រថ្មីលើការយល់ដឹងពីយេនឌ័រ និងយុត្តិធម៌អន្តរកាល។ នេះជាលើកដំបូងសម្រាប់ខ្ញុំដែលបានធ្វើការអស់ជាច្រើនឆ្នាំ តែមិនបានផ្តោតលើយុត្តិធម៌ | ជារឿយៗ ប្រឈមនឹងការបញ្ជាក់ឲ្យច្បាស់ និងផ្តល់ការបកស្រាយច្រើនពី routieifants យល់ច្រឡំ | វាល្អសម្រាប់អ្នកចូលរួមបានយល់ពីយុត្តិធម៌អន្តរកាល និងទទួលបទពិសោធន៍ជាមួយនឹងប្រព័ន្ធទំនាក់ទំនង Skype និងពីផលប៉ះពាល់ទៅលើវប្បធម៌ និងសង្គម ព្រម | គប្បីដឹកនាំសិស្សឲ្យមក ទស្សនាស្ថាប័ន គោលដៅ ដូចជា អ.វ.ត.ក ឬ អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) ឬ |

| | | | | | |
|---|---|---|---|---|---|
| | | អន្តរកាល និង អំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសង្គម | | ទាំងផ្តត់គំនិត | ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស (CDP) |
| LICADHO | វាមានប្រយោជន៍ | -យុត្តិធម៍អន្តរកាល<br>-សំណង<br>-ការបំពានល្មើសទៅលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម | វាល្អ ព្រោះអ្នកចូលរួមមានជំនាញក្នុងប្រធានបទនេះ ហើយបង្ហាញយើងនូវបទពិសោធន៍ល្អៗពីប្រទេសផ្សេងៗ | គ្មាន | ចំណាយថវិកាច្រើនទៅលើទីកន្លែងធ្វើសិក្ខាសាលា យើងគប្បីជ្រើសរើសកន្លែងផ្សេងដែលចំណាយអស់តិចជាងនេះ |
| WMC | វាមានប្រយោជន៍ និងយល់ដឹងច្រើនពីយុត្តិធម៍អន្តរកាល | -ការស្វែងរកការពិត<br>-យុត្តិធម៍<br>-សំណង | យល់ដឹងច្រើនអំពីយុត្តិធម៍អន្តរកាល<br>-មិនត្រឹមតែសម្រាប់ អ.វ.ត.ក ប៉ុណ្ណោះទេ យើងជជែកពីការងារខាងក្រៅ និងអង្គការក្រៅរដ្ឋាភិ | ការយល់ដឹងពីយេនឌ័រ និងយុត្តិធម៍អន្តរកាលជាខ្មែរគឺងាយស្រួលស្តាប់យល់ ដូច្នេះអ្នកគួរបកស្រាយឲ្យបានច្បាស់ជាងនេះ | ខ្ញុំចង់បានសិក្ខាសាលាបែបនេះទៀត សម្រាប់សិស្ស និស្សិត ផងដែរ |

| | | | | | |
|---|---|---|---|---|---|
| | | | បាល | | |
| LSCW | បាទ/ចាស ខ្ញុំយល់ថាវាសំខាន់។ ខ្ញុំបានយល់អំពីយុត្តិធម៌អន្តរកាល ដែលវាថ្មីបំផុតសម្រាប់ខ្ញុំទាក់ទង នឹងការងារធ្វើការជាមួយស្ត្រីរបស់ខ្ញុំ។ ទទួលបានបទពិសោធន៍ពីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ | ចំពោះនិយមន័យ ពាក្យថា យុត្តិធម៌អន្តរកាល (គណៈកម្មាធិការស្វែងរកការពិត សំណងយុត្តិធម៌ និងការមិនកើតឡើងជាថ្មីម្តងទៀត) ព្រមទាំងការធ្វើបទបង្ហាញលក្ខណៈបច្ចេកវិទ្យាអំពីផលវិបាករបស់ស្ត្រីក្នុងដំណើរការទទួលបានយុត្តិធម៌ពេញលេញ | ផ្តល់ពេលវេលាច្រើន សម្រាប់សំណួរនិងចម្លើយ | ផ្តល់ភាពលម្អិតពីអ.វ.ត.ក និងបញ្ហាថវិការបស់អ.វ.ត.ក | គ្មាន |
| | វាមានសារៈសំខាន់សម្រាប់ខ្ញុំ | យុត្តិធម៌អន្តរកាល | សិក្ខាសិលានេះបានធ្វើឲ្យខ្ញុំយល់ដឹងពីយេនឌ័រ និងការអនុវត្ត ជាក់ស្តែង | ខ្ញុំចង់ឲ្យមានសិក្ខាសាលាបែបនេះទៀត ហើយបកស្រាយឲ្យ | សូមផ្តល់ឯកសារ ឬស៊ីឌីដែលពាក់ព័ន្ធនឹង |

| | | | | | |
|---|---|---|---|---|---|
| | | | នៅប្រទេសទីម័រ | បានច្រើនពីយេនឌ័ររួមទាំងការអនុវត្តជាក់ស្ដែងពាក់ព័ន្ធនឹងយេនឌ័រ | យេនឌ័រ |

III. **មិនកម្មវិធី**

លោកស្រី Reiger បានបិទសិក្ខាសាលា និងថ្លែងអំណរគុណដល់ការចូលរួមរបស់អង្គការទាំងអស់។ មានការពិភាក្សាល្អឥតខ្ចោះជាច្រើន ហើយការប្រឈមគឺថា តើអ្នកចូលរួមត្រូវយកយុទ្ធសាស្ត្រមួយចំនួនដែលពួកគាត់បានរៀនសូត្រទៅអនុវត្តនៅកន្លែងធ្វើការរបស់ពួកគាត់ ដោយរបៀបណា នៅពេលពួកគាត់ត្រលប់ទៅវិញ។

**ការសង្ខេបពីវគ្គបណ្ដុះបណ្ដាល**

- ការយល់ដឹងអំពីយេនឌ័រតម្រូវឲ្យបុគ្គលទាំងអស់នៅក្នុងស្ថាប័នមានការយល់ដឹងអំពីឥទ្ធិពលនៃវប្បធម៌/ផ្នត់គំនិតសង្គមក្នុងការងាររបស់ពួកគាត់ និងការចាត់វិធានការវិជ្ជមាន ដើម្បីជម្នះឧបសគ្គនានា និងដើម្បីឈានទៅសម្រេចគោលដៅប្រកបដោយគុណភាព។
- អ.វ.ត.ក ពិតជាមានតួនាទីសំខាន់ ប៉ុន្តែ អ.វ.ត.ក តែឯកឯងមិនអាចផ្ដល់ "យុត្តិធម៌ពេញលេញ" ទេ
- ឱកាសផ្សេងៗទៀតត្រូវតែបង្កើតឡើង ដើម្បីជួយលើកកម្ពស់យុត្តិធម៌ តាមគ្រប់រូបបរិវត្តន៍សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មខាងយេនឌ័រ ក្នុងប្រទេសកម្ពុជា។

**បញ្ជីរាយនាមឧបសម្ព័ន្ធ**

**-ឧបសម្ព័ន្ធ ១៖ របៀបវារៈ**

**-ឧបសម្ព័ន្ធ ២៖ ការបែងចែកភេទរបស់ជនរងគ្រោះ ដែលចូលរួមជាមួយកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក**

**ឧបសម្ព័ន្ធ ១÷ របៀបវារៈ**

| ពេលវេលា | សកម្មភាព |
|---|---|
| ៨:៣០-៩:០០ ព្រឹក | ការចុះឈ្មោះ |
| ៩:០០-៩:១០ ព្រឹក | មតិស្វាគមន៍របស់អង្គភាពគាំពារជនរងគ្រោះ |
| ៩:១០-៩:៣០ ព្រឹក | ការណែនាំ និងការពន្យល់ពាក្យគន្លឹះៗដែលពាក់ព័ន្ធ<br>តើយុត្តិធម៌អន្តរកាលជាអ្វី? ហេតុអ្វីបានជាវានៅតែពាក់ព័ន្ធនឹងប្រទេសកម្ពុជា?<br>តើអ្វីទៅជាការយល់ដឹងអំពីយេនឌ័រ? |
| ៩:៣០-១០:០០ ព្រឹក | **តើអ្នកមានដឹងថា អំពើហិង្សាទាក់ទងនឹងផ្លូវភេទ ព្រមទាំងយេនឌ័រក្នុងប្រទេសកម្ពុក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងក្រោយមកមានអ្វីខ្លះ? តើប្រទេសកម្ពុជាបានធ្វើអ្វីខ្លះកន្លងមក ដើម្បីដោះស្រាយបញ្ហាកេរតំណែលពីអតីតកាលនេះ? តើកេរតំណែលទាំងនេះមានទំនាក់ទំនងយ៉ាងណា ជាមួយនឹងទម្រង់នៃអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រនាពេលបច្ចុប្បន្ននេះ?**<br>វាគ្មិននេះនឹងនិយាយដោយសង្ខេបឡើងវិញម្តងទៀតពីការងារនាពេលថ្មីៗនេះ ដែលចង្អុលបង្ហាញពីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានលក្ខណៈរីករាលដាលជាងការគិតរបស់សាធារណជនទូទៅ ព្រមទាំងឆ្លុះបញ្ចាំងអំពីការខិតខំប្រឹងប្រែងរកយុត្តិធម៌អន្តរកាលមកដល់សព្វថ្ងៃ។ តើស្ត្រី និងបុរស បានទទួលបទពិសោធន៍ពីរបបខ្មែរក្រហមដូចគ្នាដែរឬទេ? |
| ១០:០០-១០:៤៥ ព្រឹក | **មេរៀនអំពីយេនឌ័រ និងយុត្តិធម៌អន្តរកាលក្នុងបរិបទស្រដៀងគ្នា**<br>វាគ្មិននេះនឹងផ្តល់សេចក្តីសង្ខេបសំខាន់ៗពីមេរៀន ដែលទាញបានពីបរិបទក្រោយពេលជម្លោះ រួមមានទាំងរបៀបដែលវប្បធម៌នៃអំពើហិង្សា និងវប្បធម៌នៃការរួចផុតពីទោសទណ្ឌមានផលប៉ះពាល់ខុសៗគ្នាទៅលើស្ត្រី និងបុរស ព្រមទាំងរបៀបដែលការឆ្លើយតបនឹងយុត្តិធម៌អន្តរកាលបានវិវត្តតាំងពីពេលកកើតមក។ តើការឆ្លើយតបទាំងនេះមានផលប៉ះពាល់ទាំងលើបទពិសោធន៍នៃការឈឺចាប់ ដែលពួកគាត់បានទទួលដោយរបៀបណា និងជួយឲ្យពួកគាត់ទទួលបាន ការជួសជុលការឈឺចាប់ប្រកបដោយប្រសិទ្ធភាពដោយរបៀបណា? |

| | |
|---|---|
| ១០:៤៥-១១:០០ ព្រឹក | **សម្រាកអាហារសម្រន់** |
| ១១:០០-១១:២០ ព្រឹក | យុត្តិធម៌យេនឌ័រសម្រាប់ឧក្រិដ្ឋកម្មពីអតីតកាលក្នុងប្រទេសឥណ្ឌូនេស៊ី និងប្រទេសទីម័រខាងកើត (ការធ្វើបទបង្ហាញជាវីដេអូដោយលោកស្រី Galuh Wandita |
| ១១:២៥-១២:១៥ ព្រឹក | ធ្វើលំហាត់ (៣០ នាទី) និងរាយការណ៍ត្រលប់មកវិញ |
| ១២:១៥-១:៣០ រសៀល | សម្រាកពិសារអាហារថ្ងៃត្រង់ |
| ១:៣០-២:០០ រសៀល | **តើអ.វ.ត.កបានព្យាយាមរកយុត្តិធម៌ ចំពោះអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រកន្លងមកដោយរបៀបណា?**<br>ការធ្វើបទបង្ហាញរយៈពេលខ្លីនេះនឹងសម្លឹងមើលត្រួសៗថាតើអ.វ.ត.ក បានផ្តល់យុត្តិធម៌ចំពោះឧក្រិដ្ឋកម្មយេនឌ័រក្នុងសំណុំរឿង ចំពោះមុខខ្លួនបានកម្រិតណា និងទៅលើភាពមានកម្រិតនៃកិច្ចដំណើរការនីតិវិធីចំពោះបញ្ហានេះ |
| ២:០០-៣:១៥ រសៀល | **ដំណើរឆ្ពោះទៅមុខពីការយល់ដឹងអំពីយេនឌ័រ និងយុត្តិធម៌អន្តរកាលក្នុងប្រទេសកម្ពុជា**<br>អ្នកចូលរួមនឹងត្រូវបំបែកទៅជាក្រុមតូចៗ ដើម្បីមានឱកាសបង្កើនប្រសិទ្ធភាពការងារ និងរកយុទ្ធសាស្ត្រដែលអាចទៅរួចដោយលម្អិត ចំពោះយុត្តិធម៌យេនឌ័រសម្រាប់ឧក្រិដ្ឋកម្មពីអតីតកាលក្នុងប្រទេសកម្ពុជា |
| ៣:១៥-៣:៣០ រសៀល | **សម្រាកអាហារសម្រន់** |
| ៣:៣០-៤:០០ រសៀល | រាយការណ៍ត្រលប់មកវិញ និងការពិភាក្សា |
| ៣:៣០-៤:០០ រសៀល | ការវាយតម្លៃ និងបិទកម្មវិធី |

## ឧបសម្ព័ន្ធ២៖ ការបែងចែកភេទរបស់ជនរងគ្រោះ ដែលចូលរួមជាមួយកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក[1]

| **ការចូលរួមរបស់ជនរងគ្រោះ** | | **ការការពារដែលបានស្នើសុំ?** (ទាំងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកប្តឹង) | |
|---|---|---|---|
| ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់តាមភេទ | ៣៨៦៤ | | |
| បុរស | ៣៩% | បុរស | ១២% |
| ស្ត្រី | ៦១% | ស្ត្រី | ១៤.៥៩% |
| ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ | ១៩៩ | | |
| បុរស | ៤១% | | |
| ស្ត្រី | ៥៩% | | |
| អ្នកប្តឹង | ៤១២៨ | | |
| បុរស | ៤២% | | |
| ស្ត្រី | ៥៧% | | |
| **សំណងត្រូវគេរកឃើញថាមាន ៩៤% ទាំងបុរស និងស្ត្រី** | | | |
| បុរស | ៣៩% | | |
| ស្ត្រី | ៦១% | | |

[1] ផ្អែកតាមព័ត៌មានផ្តល់ដោយអ.វ.ត.ក/អង្គភាពគាំពារជនរងគ្រោះ

| ប្រភេទនៃសំណងដែលគេប្រទះ | បុរស | ស្ត្រី | សរុប | បុរស | ស្ត្រី |
|---|---|---|---|---|---|
| សេវាសុខាភិបាល | ៤០៦ | ៨០៦ | ១២១២ | ៣៣% | ៦៧% |
| សាលារៀន | ៣៩៩ | ៦០០ | ៩៩៩ | ៤០% | ៦០% |
| ហេដ្ឋារចនាសម្ព័ន្ធ | ៣៩៤ | ៥៦៩ | ៩៦៣ | ៤១% | ៥៩% |
| សំណងលក្ខណៈបុគ្គល | ២៨៦ | ៦៣៥ | ៩២១ | ៣១% | ៦៩% |
| យុត្តិធម៌ | ៣៣២ | ៤៧៩ | ៨១១ | ៤១% | ៥៩% |
| បូជនីយដ្ឋាន | ២២៦ | ៣៤៣ | ៥៦៩ | ៤០% | ៦០% |
| ការរក្សាទុកឯកសារឧក្រិដ្ឋកម្មខ្មែរក្រហម | ១៥៤ | ២៨១ | ៤៣៥ | ៣៥% | ៦៥% |
| ការកសាងផ្នែកសាសនា | ១៤៤ | ១៩២ | ៣៣៦ | ៤៣% | ៥៧% |
| សមូហភាព មិនបញ្ជាក់ | ១២៩ | ១៧៨ | ៣០៧ | ៤២% | ៥៨% |
| ពិធីបុណ្យសព | ៧៤ | ២០៩ | ២៨៣ | ២៦% | ៧៤% |
| សំណងផ្សេងៗ | ១៤ | ៥ | ១៩ | ៧៤% | ២៦% |

- ការទាមទារស្មើគ្នាចំពោះ៖ សាលារៀន, ហេដ្ឋារចនាសម្ព័ន្ធ, យុត្តិធម៌, បូជនីយដ្ឋាន
- ស្ត្រីច្រើនជាងបុរសដែលចង់បានសេវាសុខភាព, សំណងជាលក្ខណៈបុគ្គល, ការរក្សាទុកឯកសារ, ពិធីបុណ្យសព
- បុរសច្រើនជាងស្ត្រីចង់បានការកសាងផ្នែកសាសនា សំណងជាលក្ខណៈសមូលហភាពផ្សេងៗ។